ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការត្រួតពិនិត្យជម្ងឺអុតក្តាម




រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ លោក ម៉ារី ម៉ាឃ្លីន** (Murray Maclean)

**កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៏ អន្តរជាតិ (AusAID)តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ននិងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹង ដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយក ទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម តាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋា*ភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និង អ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និង ទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា"។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យាដើម្បីជួយដោះស្រាយ បញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៏កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើន ដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗ របស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ននានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអបត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួត ពិនិត្យរបស់ក្រុមការងារបអបបន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

## មាតិកា


**១. សេចក្តីអធិប្បាយ** ........ ១

**២. ការណែនាំបច្ចេកទេស** ........ ៣

២.១- សង្ខេបការណែនាំបច្ចេកទេស ........ ៣

២.២- ការកត់សំគាល់លើការណែនាំបច្ចេកទេស ........ ៣

*២.២.១ ចាក់វ៉ាក់សាំងជម្ងឺអុតក្តាមដល់គោ ក្របី ជ្រូក និងពពែរបស់អ្នក នៅពេលមានជម្ងឺអុត ក្តាមផ្ទុះ ឡើងនៅភូមិ ឃុំ ស្រុកជិតខាង* ........ ៣

*២.២.២. សូមប្រយ័ត្ន ! កុំឱ្យសត្វឈឺប៉ះពាល់ជាមួយសត្វជា* ........ ៨

*២.២.៣ នៅពេលដែលសត្វរបស់អ្នកឈឺ សូមទាក់ទងភ្នាក់ងារសុខភាពសត្វភូមិជាបន្ទាន់* ........ ៨

២.៣- ផលចំណេញផ្នែកសេដ្ឋកិច្ច ........ ៩

**៣. ការណែនាំលើការងារផ្សព្វផ្សាយ** ........ ១១

៣.១- ការរៀបចំស្ថាប័ន ........ ១១

៣.២- ផែនការសកម្មភាព ........ ១១

៣.៣- ឧបករណ៍, សម្ភារៈ ........ ១៥

៣.៤- ថវិកាសម្រាប់ការធ្វើបង្ហាញ ........ ១៧

៣.៥- ទីកន្លែងអនុវត្តទីតាំងគំរោង ........ ១៩

**៤. ឧបសម្ព័ន្ធ** ........ ២០

៤.១ ឧបសម្ព័ន្ធទី ១ : សៀវភៅកត់ត្រាសម្រាប់អ្នកគ្រប់គ្រងស្រុក ........ ២០

៤.២ ឧបសម្ព័ន្ធទី ២ : សៀវភៅកត់ត្រាសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ ........ ២៣

៤.៣ ឧបសម្ព័ន្ធទី ៣ : ខិត្តប័ណ្ណព័ត៌មានអំពីជម្ងឺអុតក្តាម ........ ២៥

៤.៤ ឧបសម្ព័ន្ធទី ៤ : ផ្ទាំងរូបភាព និងខិត្តប័ណ្ណផ្សព្វផ្សាយពីការផ្ទុះជម្ងឺអុតក្តាម ........ ២៦

៤.៥ ឧបសម្ព័ន្ធទី ៥ : ផ្ទាំងរូបភាព ផ្សព្វផ្សាយពីថ្ងៃចាក់វ៉ាក់សាំងជម្ងឺអុតក្តាម ........ ២៧

៤.៦ ឧបសម្ព័ន្ធទី ៦ : ខិត្តប័ណ្ណក្រោយពេលចាក់វ៉ាក់សាំងជម្ងឺអុតក្តាម ........ ២៨

៤.៧ ឧបសម្ព័ន្ធទី ៧ : ព័ត៌មានខ្លីៗសម្រាប់ផ្សព្វផ្សាយជម្ងឺអុតក្តាម ........ ២៩

## ១. សេចក្តីអធិប្បាយ

| | |
|---|---|
| **ឈ្មោះអត្ថបទ** | ការត្រួតពិនិត្យជម្ងឺអុតក្តាម |
| **កាលបរិច្ឆេទ** | ខែមករា ឆ្នាំ ២០០៦ |
| **ប្រភពបទដ្ឋានអនុវត្តបច្ចេកទេស** | Murray Maclean |
| **គោលបំណង និងសារៈប្រយោជន៍** | ដើម្បីបង្កើនចំណេះ និងការយល់ដឹងរបស់ប្រជាកសិករ អំពីជម្ងឺអុតក្តាម<br>ដើម្បីបង្កើនជីវភាពរស់នៅរបស់កសិករដោយការពារគោ ក្របី ជ្រូក របស់ពួកគាត់កុំឱ្យកើតមានជម្ងឺអុតក្តាម ។<br>កសិករទទួលផលប្រយោជន៍ ដោយគ្មានជម្ងឺអុតក្តាមកើតមានលើសត្វ ដែលជាកំលាំងអូសទាញ ហើយទាំងមិនបណ្តាលឱ្យកូនគោងាប់ដែរ ។<br>វានឹងធ្វើឱ្យទំនាក់ទំនងកាន់តែប្រសើរឡើង រវាងអ្នកបច្ចេកទេស និង អ្នកផ្សព្វផ្សាយ និងក្នុងចំណោមអ្នកពាក់ព័ន្ធដទៃទៀត ។ |

**លក្ខខណ្ឌសមស្របទៅតាមបច្ចេកទេស**

ការផ្ទុះជម្ងឺអុតក្តាមនាពេលបច្ចុប្បន្ននៅក្នុងឃុំ ឬប្រទេសជិតខាង

**ការចូលទិន្នន័យសំខាន់ៗ**

- មានការចូលរួមដ៏សកម្ម ពីភ្នាក់ងារសុខភាពសត្វភូមិក្នុងការផ្តល់សេវាសុខភាពសត្វ។ ភ្នាក់ងារសុខភាពសត្វភូមិ គឺមានប្រសិទ្ធភាព ប្រសិនបើកសិករនៅក្នុងភូមិដឹង និងជឿជាក់លើភ្នាក់ងារសុខភាពសត្វភូមិក្នុងការព្យាបាលសត្វឈឺ ។ ការិយាល័យផលិតកម្ម និងបសុព្យាបាល និងអង្គការក្រៅរដ្ឋាភិបាល អាចជាប្រភពព័តិមានមួយថាតើភ្នាក់ងារសុខភាពសត្វភូមិមានប្រសិទ្ធភាព ឬអត់។ ការចុះមើល និងជួបជាមួយកសិករ និងភ្នាក់ងារសុខភាពសត្វភូមិ គឺជាមធ្យោបាយដ៏ល្អបំផុត ដើម្បីកំណត់អំពីប្រសិទ្ធភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិ។
- មន្ត្រីបសុពេទ្យស្រុកដែលមានសមត្ថភាព
- ថ្នាំបង្ការជម្ងឺអុតក្តាម ការផ្ទុះជម្ងឺអុតក្តាមកើតឡើងរៀងរាល់ ២-៣ឆ្នាំម្តងលើតំបន់ជាច្រើន ។

ក្នុង “បទដ្ឋានអនុវត្តបច្ចេកវិទ្យា” នេះ គឺសំដៅលើកសិករដែលចិញ្ចឹម គោ ក្របី និងជ្រូក ដូច្នេះស្ថានភាពសេដ្ឋកិច្ចរបស់កសិករ ដែលបានទទួលក្នុងគំរោងនេះ គឺមានការប្រែប្រួលពីក្រទៅមាន។

កសិករត្រូវការប្រហែល ៦០០០រៀល ដើម្បីចាក់វ៉ាក់សាំងដល់គោ ក្របី និងជ្រូកមួយក្បាល ។

## ២. ការណែនាំបច្ចេកទេស

### *២.១- សង្ខេបការណែនាំបច្ចេកទេស*

ក. ចាក់វ៉ាក់សាំងជម្ងឺអុតក្តាមដល់គោ ក្របី ជ្រូក និងពពែរបស់អ្នក នៅពេលមានជម្ងឺអុតក្តាមផ្ទុះឡើងនៅ ភូមិ ឃុំ ស្រុកជិតខាង ។

ខ. សូមប្រយ័ត្ន កុំឱ្យសត្វឈឺ ប៉ះពាល់ជាមួយសត្វជា

គ. នៅពេលសត្វរបស់អ្នកឈឺ សូមទាក់ទងជាមួយភ្នាក់ងារសុខភាពសត្វភូមិជាបន្ទាន់

### *២.២- ការកត់សំគាល់លើការណែនាំបច្ចេកទេស*

### ២.២.១ ចាក់វ៉ាក់សាំងជម្ងឺអុតក្តាមដល់គោ ក្របី ជ្រូក និងពពែរបស់អ្នក នៅពេលមានជម្ងឺអុតក្តាមផ្ទុះឡើងនៅ ភូមិ ឃុំ ស្រុកជិតខាង

*ជម្ងឺអុតក្តាមនៅក្នុងប្រព័ន្ធកសិកម្មបុរាណក្នុងប្រទេស*

នៅក្នុងប្រទេសកម្ពុជា ជម្ងឺអុតក្តាមអាចបណ្តាលមកពីវីរុសបីប្រភេទផ្សេងៗគ្នាគឺប្រភេទ O, A និង Asia 1។ រោគសញ្ញានៃជម្ងឺអុតក្តាមដែលបង្កឡើងដោយវីរុសទាំងបីប្រភេទនេះ គឺមានលក្ខណៈដូចគ្នា។

ជម្ងឺអុតក្តាមគឺជាជម្ងឺឆ្លងពីសត្វទៅសត្វ វាកើតឡើងក្នុងទម្រង់ផ្ទុះជម្ងឺ។ ជាទូទៅអត្រាដែលសត្វទទួលរងនូវ ជម្ងឺនេះខ្ពស់គឺសត្វគោ ក្របី និងជ្រូក ។ ជម្ងឺនេះវារីករាលដាលយឺតៗតាមរយៈតំបន់ដែលមានជម្ងឺ ។ ជាធម្មតាការផ្ទុះជម្ងឺជាទ្រង់ទ្រាយធំ កើតឡើងនៅចន្លោះពេលជាច្រើនឆ្នាំ។

ការសំងំនៃជម្ងឺមានរយៈពេល ពី ២-១៤ថ្ងៃ។ វីរុសវាយប្រហារលើ ជើង មាត់ និងក្រពេញទឹកដោះនៃសត្វគោក្របីដែលទទួលរងជម្ងឺនេះ។ ជាលទ្ធផលបង្ហាញដូចខាងក្រោម ៖

- សត្វមានសីតុណ្ហភាពខ្ពស់ និងអន់ស៊ីចំណីរយៈពេល ១-២សប្តាហ៍។ សត្វស្រកទម្ងន់ ហើយមិនសូវមានទឹកដោះឱ្យកូនបៅ (សត្វមេ)។
- ពិការក្រចកជើងមិនអាចដើរ ដើម្បីទៅវាលស៊ីស្មៅ និងមិនអាចភ្ជួររាស់រៀបចំដី និងអូសរទេះបាន
- កូនគោមិនអាចបៅដោះមេវាងាយស្រួលឡើយ
- មេគោខ្លះអាចនឹងរលូតកូន

នៅលើជើងសត្វដែលទទួលរងជម្ងឺអុតក្តាមនេះ អាចមានបាក់តេរីឆ្លងចូល ហើយអាចបន្តឱ្យសត្វឈឺមានរយៈពេលរឹតតែវែង ។

ស្ទើរតែគ្រប់សត្វគោ និងក្របីពេញវ័យទាំងអស់ ជាសះស្បើយពីជម្ងឺនេះនៅកំឡុងពេល ២-៣សប្តាហ៍ ទោះបីជាយ៉ាងនេះក៏ដោយមានអត្រាតិចតួចណាស់ដែលកូនគោនេះងាប់ នៅពេលជម្ងឺនេះវាយប្រហារទៅលើមុខងារបេះដូង ។

ចំពោះជ្រូក ជម្ងឺអុតក្តាមបណ្តាលឱ្យកូនជ្រូកងាប់ ហើយបើមិនងាប់ទេ វាបន្តឱ្យកើតដំបៅលើជើង ធ្វើឱ្យមានការប៉ះពាល់ដល់ការលូតលាស់របស់កូនជ្រូក ។

វីរុសរីករាលដាលតាមរយៈការប៉ះពាល់ជិតដិតរវាងសត្វឈឺ និងសត្វជា ឬតាមរយៈសត្វជា ប៉ះពាល់ជាមួយបរិស្ថានដែលកខ្វក់ ឬភក់ដែលប្រឡាក់ប្រឡូកទៅដោយមេរោគ ។ សត្វឈឺអាចចម្លងវីរុសរយៈពេលរហូតដល់ ១០ថ្ងៃឡើងមុនពេលវាបង្ហាញរោគសញ្ញា ។



*ជម្ងឺអុតក្តាមអាចបណ្តាលឱ្យកូនគោងាប់ នៅពេលដែលវីរុសវាយប្រហារលើសាច់ដុំបេះដូង*




*កូនជ្រូកភាគច្រើន ប្រហែលជាងាប់នៅកំឡុងពេលផ្ទុះជម្ងឺអុតក្តាម ហើយកូនជ្រូកភាគច្រើនដែលនៅរស់នឹងមានបញ្ហាជើងរ៉ាំរ៉ៃ និងលូតលាស់យឺត*

គ្មានបសុឱសថណាអាចសំលាប់វីរុសទាំងបីប្រភេទនេះបានឡើយ ។ ទោះជាយ៉ាងណាក្តី ការព្យាបាលអាចកាត់បន្ថយការរីករាលដាលនៃជម្ងឺនេះ ។

គោ ក្របីដែលជាសះស្បើយពីជម្ងឺ នឹងមានលទ្ធភាពការពារប្រឆាំងនឹងប្រភេទវីរុសដែលនាំឱ្យវាឈឺនោះ ក្នុងកំឡុងពេលប្រហែល ១៨ខែ ប៉ុន្តែវាមិនអាចការពារនឹងជម្ងឺនេះដែលបង្កឡើងដោយវីរុសប្រភេទផ្សេងបានឡើយ ។

ប្រសិនបើសត្វបានចាក់ថ្នាំបង្ការចំពោះវីរុសប្រភេទមួយ ហើយចាក់លើកទី២នៅខែបន្ទាប់ វាអាចការពារជម្ងឺដែលបង្កឡើងដោយវីរុសប្រភេទនោះរយៈពេល៦-១២ខែ អាស្រ័យទៅលើអាយុប្រវត្តិជម្ងឺ និងប្រវត្តិនៃការចាក់វ៉ាក់សាំងរបស់សត្វ ។ ការចាក់ថ្នាំបង្ការប្រភេទវីរុសមួយ អាចការពារបានតែជម្ងឺមួយប្រភេទនោះតែប៉ុណ្ណោះ មិនអាចការពារជម្ងឺដែលបង្កឡើងដោយវីរុសប្រភេទផ្សេងបានឡើយ ។ ប្រសិនបើគោ ក្របីឈឺដែលបង្កដោយវីរុសប្រភេទណាមួយពី មុន ពួកវាប្រហែលជាអាចការពារជាមួយនឹងជម្ងឺប្រភេទនោះរហូត ដល់ ១២ខែបន្ទាប់ពីចាក់ថ្នាំបង្ការម្តង ។

**ក្រុមហ៊ុនផលិតវ៉ាក់សាំងអាចមាន**

- វ៉ាក់សាំងជម្ងឺដែលបង្កឡើងដោយវីរុសមួយប្រភេទ តួយ៉ាងដូចជា ថ្នាំបង្ការវីរុសប្រភេទ O ។ ថ្នាំបង្ការនេះហៅថា **ម៉ូណូវ៉ាឡង់** ។
- ថ្នាំបង្ការជម្ងឺដែលបង្កឡើងដោយវីរុសច្រើនប្រភេទ ដែលជាទូទៅភាគច្រើនត្រូវបានប្រើប្រាស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលថ្នាំបង្ការ នេះហៅថា ទ្រីវ៉ាឡង់ ដោយមានផ្ទុកវីរុសប្រភេទ O, A, និង Asia 1 ។ ហើយវ៉ាក់សាំង ទ្រីវ៉ាឡង់ នោះមានតម្លៃថ្លៃជាង ម៉ូណូវ៉ាឡង់ ។

**វ៉ាក់សាំងជម្ងឺអុតក្តាម**

- ត្រូវថែរក្សាទុកនៅកន្លែងត្រជាក់ជាប់ជានិច្ច ចាប់តាំងពីកន្លែងផលិតរហូតដល់ពេលចាក់ បើមិនដូច្នោះទេ ថ្នាំបង្ការទាំងនោះនឹងគ្មានប្រសិទ្ធភាព ។
- ត្រូវចាក់ថ្នាំតាមបច្ចេកទេសបសុពេទ្យ នៅគ្រប់ពេលចាក់វ៉ាក់សាំង

នៅក្នុងប្រទេសកម្ពុជា វ៉ាក់សាំងជម្ងឺសត្វកំរមានគេប្រើណាស់ លើកលែងតែក្នុងស្ថានភាពខ្លះ ដែលរាជរដ្ឋា ភិបាលអាចផ្តល់ជាមូលនិធិសង្គ្រោះបន្ទាន់ ។ ការផ្ទុះជម្ងឺនៅតែបន្តរីករាលដាល នៅពេលដែលមានការកើនឡើងការធ្វើចលនាសត្វគោ-ក្របី ពីតំបន់មួយទៅតំបន់មួយដើម្បីប្រើជាកំលាំងអូសទាញក្នុងកំឡុងពេលមាត់ និងជើងរបស់សត្វឈឺ ។

ក្នុងពេលផ្ទុះជម្ងឺអុតក្តាម កសិករព្យាបាលដោយប្រើឱសថបុរាណ ដោយព្យាបាលនៅកន្លែងដែលសត្វឈឺ ដូចជានៅលើជើង មាត់ និងចាក់ថ្នាំផង ។ ជាទូទៅ ការផ្ទុះជម្ងឺមានដំណើរការយ៉ាងពេញទំហឹងតាមកំលាំងរបស់វា ។

**កសិករភាគច្រើន**

- ដឹងពីរោគសញ្ញានៃជម្ងឺអុតក្តាម ដែលភាគច្រើនបានឃើញរោគសញ្ញានេះនៅពេលណាមួយ
- អាចស្គាល់រោគសញ្ញាដែលប្រុងនឹងលេចចេញជាជម្ងឺអុតក្តាម
- មិនយល់ពីកម្មវិធីចាក់ថ្នាំបង្ការជាប្រចាំដែលរៀបចំឡើងដោយរដ្ឋាភិបាលសម្រាប់ការពារជម្ងឺសាទឹកគោ ក្របី ហើយវាមិនអាចការពារជម្ងឺអុតក្តាមបានទេ ។
- មិនដឹងថា មានថ្នាំបង្ការសម្រាប់ការពារជម្ងឺអុតក្តាមផង
- មិនចង់ចំណាយលុយលើការចាក់ថ្នាំការពារ នៅពេលដែលសត្វរបស់គាត់មានសុខភាពល្អ ដោយគាត់គិតថាគ្មានចំណេញអ្វីសម្រាប់គាត់ គឺគាត់រំពឹងលើយុទ្ធនាការរបស់រដ្ឋាភិបាល ឬក៏គំរោងរបស់អង្គការនានា ដើម្បីចេញប្រាក់ចំណោយលើវ៉ាក់សាំង និងសេវាកម្មផ្សេងៗ ។

នៅពេលផ្ទុះជម្ងឺ ការិយាល័យផលិតកម្ម និងបសុព្យាបាល ប្រហែលជាចុះទៅប្រមូលយកវត្ថុវិភាគពីសត្វឈឺ និងបញ្ជូនមក នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលដើម្បីវិភាគរកប្រភេទវីរុសដែលបង្កជម្ងឺអុតក្តាម ។

**អនុសាសន៍សំខាន់ៗក្នុងការចាក់វ៉ាក់សាំង**

នៅពេលដែលមានជម្ងឺផ្ទុះឡើងនៅភូមិ ឃុំជិតខាង កសិករដែលនៅតំបន់ដែលមិនទាន់ផ្ទុះជម្ងឺត្រូវ ៖

- សំណូមពរឱ្យភ្នាក់ងារសុខភាពសត្វភូមិ និងប្រធានភូមិ ផ្តល់ព័តិមានដល់ម្ចាស់សត្វ និងរៀបចំកម្មវិធីចាក់ថ្នាំបង្ការនៅក្នុងភូមិ ។
- លើកទឹកចិត្តឱ្យកសិករផ្សេងទៀតចូលរួមក្នុងការផ្តល់ព័តិមានពីការផ្ទុះជម្ងឺ និងកម្មវិធីចាក់វ៉ាក់សាំង
- អោយប្រាក់ដល់ភ្នាក់ងារសុខភាពសត្វភូមិដើម្បីទិញថ្នាំបង្ការ រួមបញ្ចូលទាំងថ្លៃធ្វើដំណើរ និងថ្លៃទឹកកកសម្រាប់ក្លាស្សេ ។
- ចាប់គោ ក្របី និងជ្រូកទុក ព្រោះភ្នាក់ងារសុខភាពសត្វភូមិអាចមកចាក់ថ្នាំបង្ការដល់ផ្ទះ ដោយគ្រាន់តែចំណាយលើថ្លៃសេវាបន្ថែម ។
- ចាក់វ៉ាក់សាំងដល់សត្វដែលទើបមកដល់ថ្មីនៅក្នុងភូមិរួមទាំងសត្វ នាំចូល ឬទើបនឹងកើត
- ផ្តល់ចំលើយតបដល់ភ្នាក់ងារសុខភាពសត្វភូមិ និងប្រធានភូមិអំពីប្រសិទ្ធភាពនៃការផ្តល់ព័តិមាន និងកម្មវិធីចាក់ថ្នាំបង្ការជម្ងឺ ហើយលើកឡើងពីសេចក្តីត្រូវការបន្ថែមក្នុងការចាក់ថ្នាំបង្ការ ។

មានវ៉ាក់សាំងជម្ងឺអុតក្តាមប្រភេទទ្រីវ៉ាឡង់ អាចបញ្ជាទិញតាមរយៈកន្លែងដេប៉ូលក់ថ្នាំសត្វនៅទីក្រុងភ្នំពេញ។ ចំណែកឯថ្នាំបង្ការជម្ងឺប្រភេទ Pfizer ទ្រីវ៉ាឡង់ អាចបញ្ជាទិញពីភ្នាក់ងាររបស់ក្រុមហ៊ុន ណាវិតកូ ។ វ៉ាក់សាំងទាំងនេះគឺជាប្រភេទដបក្នុងកំរិតផ្សេងៗគ្នា (100cc និង 50cc)។ ចំពោះរបៀបប្រើប្រាស់វ៉ាក់សាំង មានបង្ហាញជូនក្នុងតារាងខាងក្រោមនេះ ៖

**តារាងទី១ ការណែនាំលើការប្រើប្រាស់វ៉ាក់សាំងជម្ងឺអុតក្តាមប្រភេទ** Posi-FMD trivalent **ដែលផលិតដោយ** Pfizer

| របៀបប្រើប្រាស់ថ្នាំបង្ការជម្ងឺអុតក្តាមប្រភេទ Posi-FMD trivalent ដែលផលិតដោយ Pfizer | | | | |
|---|---|---|---|---|
| **ប្រភេទសត្វ** | **កំរិតប្រើ** | **អាយុដែលត្រូវចាក់ថ្នាំ** | **កម្មវិធីចាក់ថ្នាំ** | **រយៈពេលការពារជម្ងឺ** |
| គោ និង ក្របី | ២ សេ សេ ក្នុង១ក្បាល | អាយុចាប់ពី៤ខែឡើងទៅ | ចាក់២ដង ក្នុងចន្លោះ១ខែ | ៦ខែ |
| ជ្រូក | ២ សេ សេ ក្នុង១ក្បាល | អាយុចាប់ពី២ខែឡើងទៅ | ចាក់២ដង ក្នុងចន្លោះ១ខែ | ៦ខែ |
| ពពែ | ១ សេ សេ ក្នុង១ក្បាល | អាយុចាប់ពី៣ខែឡើងទៅ | ចាក់២ដង ក្នុងចន្លោះ១ខែ | ៦ខែ |

## ទីផ្សារលក់ថ្នាំបង្ការ

តម្រូវការថ្នាំបង្ការជម្ងឺអុតក្តាមនាពេលបច្ចុប្បន្ននេះ គឺតិចតួចណាស់ ។ ក្នុងករណីគ្មានយុទ្ធនាការស្វែងរកទីផ្សារ តម្រូវការថ្នាំបង្ការជម្ងឺអុតក្តាមនៅតែមានកំរិតទាបដដែល ទោះបីជាយ៉ាងនេះក៏ដោយមានការចង្អុលបង្ហាញថា តម្រូវការនឹងអាចកើនឡើងតាមរយៈការស្វែងរកទីផ្សារយ៉ាងសកម្មនៅពេលមានជម្ងឺអុតក្តាមផ្ទុះឡើងនៅតំបន់ជិតខាង ។




*ថ្នាំបង្ការជម្ងឺអុតក្តាម នាំចូលពីប្រទេសវៀតណាម*
*ថ្នាំបង្ការត្រូវទុកនៅកន្លែងត្រជាក់រហូតដល់ពេលចាក់*



*ថ្នាំការពារជម្ងឺអុតក្តាម មិនមែនមានលក់គ្រប់កន្លែង ឬតូបលក់ថ្នាំសត្វទេប៉ុន្តែអាចរកបានតាមរយៈការប្រើប្រាស់បណ្តាញទីផ្សារមានស្រាប់*

ដើម្បីឱ្យកម្មវិធីចាក់ថ្នាំបង្ការទទួលបានជោគជ័យ គួរតែផ្តល់ប្រាក់លើកទឹកចិត្តគ្រប់គ្រាន់ ដល់ភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីឱ្យពួកគេចូលរួមក្នុងការងារនេះ ។ តារាងខាងក្រោមជាការផ្តល់ជាឧទាហរណ៍នៃប្រាក់ចំណូលរបស់ភ្នាក់ងារសុខភាពសត្វភូមិដែលទទួលខុសត្រូវចំនួនសត្វដ៏ច្រើន ។

**តារាងទី២ ប្រាក់ចំណេញជាឧទាហរណ៍របស់ភ្នាក់ងារសុខភាពសត្វភូមិបានមកពីកម្មវិធីចាក់ថ្នាំបង្ការ**

| ប្រាក់ចំណូលជាឧទាហរណ៍របស់ភ្នាក់ងារសុខភាពសត្វភូមិបានមកពីកម្មវិធីចាក់ថ្នាំបង្ការ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទសត្វ | ចំនួន (ក្បាល) | ចាក់វ៉ាក់សាំង (ភាគរយ) | ចំនួនសត្វបានចាក់វ៉ាក់សាំង(ភាគរយ) | សរុប (សេសេ) | វ៉ាក់សាំងជម្ងឺអុតក្តាម(៣០សេសេក្នុង១ដប) | តម្លៃវ៉ាក់សាំង (រៀល) | ប្រាក់ចំណូលរបស់ ភ ស ភ (រៀល) | ប្រាក់ចំណេញរបស់ ភ ស ភ (រៀល) |
| គោអូសទាញ | ១០០ | ៥០ | ៥០ | ២០០ | ៧ | ៤៨០ ០០០ | ៦០០ ០០០ | ១២០ ០០០ |
| មេគោពូជ | ១០០ | ៥០ | ៥០ | ២០០ | ៧ | ៤៨០ ០០០ | ៦០០ ០០០ | ១២០ ០០០ |
| មេជ្រូកពូជ | ១០ | ៥០ | ៥ | ២០ | ១ | ៤៨០ ០០ | ៦០០ ០០ | ១២០ ០០ |
| ជ្រូកបំប៉ន | ១៥០ | ៥០ | ៧៥ | ៣០០ | ១០ | ៧២០ ០០០ | ៩០០ ០០០ | ១៨០ ០០០ |
| សរុប | ៣៦០ | ២០០ | ១៨០ | ៧២០ | ២៤ | ១ ៧២៨ ០០០ | ២ ១៦០ ០០០ | ៤៣២ ០០០ |

**<u>ចំណាំ</u>** - ៣០ សេ សេ ក្នុង ១ដប

- ១ដប តម្លៃ ៧២ ០០០រៀល
- សម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ ចាក់វ៉ាក់សាំង ១ដូស តម្លៃ ៤ ៨០០រៀល
- សម្រាប់កសិករ ចាក់វ៉ាក់សាំង ១លើក តម្លៃ ៦ ០០០រៀល

តាមតារាងខាងលើនេះ បង្ហាញពីសក្តានុពលភាពនៃប្រាក់ចំណូលរបស់ភ្នាក់ងារសុខភាពសត្វភូមិ ដែលពួកគេគួរតែទទួលបានផលប្រយោជន៍ពីសង្គមខ្លះ បើសិនជាមានការរៀបចំកម្មវិធីចាក់បង្ការជម្ងឺអុតក្តាម ។

### ២.២.២. សូមប្រយ័ត្ន ! កុំឱ្យសត្វឈឺប៉ះពាល់ជាមួយសត្វជា

ចលនាសត្វពិបាកគ្រប់គ្រងណាស់ នៅក្នុងប្រព័ន្ធកសិកម្មក្នុងប្រទេសកម្ពុជា។ ក្នុងកំឡុងពេលផ្ទុះជម្ងឺអុតក្តាម ដែលកើតមានចំពេលរដូវភ្ជួររាស់ ដែលជាទូទៅចលនាសត្វបានកើនឡើង ពីភូមិមួយទៅភូមិមួយ ពីឃុំមួយទៅឃុំមួយ ដើម្បីបំពេញតម្រូវការកំលាំងអូសទាញ ។

នៅតាមផ្ទះក្នុងកំឡុងពេលផ្ទុះជម្ងឺចលនាសត្វប្រហែលជាថយចុះពីព្រោះនៅពេលសត្វឈឺត្រូវចងទុកនៅក្រោមផ្ទះចាប់តាំងពីសត្វពិបាកក្នុងការដើរ ។

ចំពោះភាពមិនអាចគ្រប់គ្រងបាននូវចលនាសត្វដែលកើតមានកន្លងមក គ្រួសារនីមួយៗត្រូវធ្វើការសំរេចចិត្តដោយខ្លួនឯងអំពីរបៀបគ្រប់គ្រងចលនាសត្វនៅពេលដែលមានជម្ងឺផ្ទុះឡើងនៅតំបន់ជិតខាង ហេតុដូចនេះហើយ ទើបពុំមានលទ្ធភាពក្នុងការផ្តល់អនុសាសន៍ឱ្យបានសមស្រប នូវអ្វីដែលនឹងធ្វើដើម្បីកាត់បន្ថយការប៉ះពាល់រវាងសត្វឈឺ និងសត្វមានសុខភាពល្អ ។

ដូច្នេះយុទ្ធវិធីដ៏ល្អបំផុតដើម្បីផ្តល់ព័ត៌មានដល់កសិករ នូវកត្តាបច្ចេកទេសសំខាន់ៗក្នុងការចំលងជម្ងឺ ដែលកំពុងកើតមានឡើងគឺ:

- ការចំលងជម្ងឺកើតឡើងនៅពេលសត្វឈឺប៉ះពាល់យ៉ាងជិតដិតជាមួយសត្វមានសុខភាពល្អ
- សត្វឈឺអាចរចំលងវីរុសរយៈពេល១០ថ្ងៃមុនពេលចេញរោគសញ្ញា

បញ្ហាទាំងនេះ គួរតែអាចធ្វើឱ្យកសិករមានការយល់ដឹងថា ជម្ងឺអុតក្តាមគឺជាបញ្ហាមួយនៅក្នុងភូមិ។ ម៉្យាងវិញទៀតកសិករទាំងអស់នៅក្នុងភូមិគួរតែចូលរួមក្នុងកម្មវិធីប្រយុទ្ធនឹងជម្ងឺអុតក្តាមទាំងអស់គ្នា។ ប្រសិនបើមានតែកសិករមួយចំនួនតូចចូលរួមនៅពេលដែលមានជម្ងឺអុតក្តាមផ្ទុះឡើងនៅក្នុងភូមិ ជម្ងឺនេះនឹងអាចបន្តរីករាលដាលដល់សត្វថ្មីទៀតនៅក្នុងភូមិ ហើយប្រហែលជាអាចរាលដាលដល់សត្វដែលបានចាក់ថ្នាំការពាររួចហើយទៀតផង។

### ២.២.៣ នៅពេលដែលសត្វរបស់អ្នកឈឺ សូមទាក់ទងភ្នាក់ងារសុខភាពសត្វភូមិជាបន្ទាន់

ប្រសិនបើសត្វរបស់អ្នកឈឺ អ្នកគួរតែប្រាប់ភ្នាក់ងារសុខភាពសត្វភូមិ ដែលគាត់អាចពិនិត្យមើល និងព្យាបាលសត្វរបស់អ្នកបាន និងប្រាប់គាត់ពីបញ្ហាអ្វីដែលអ្នកចង់ដឹង ។

## ២.៣- ផលចំណេញផ្នែកសេដ្ឋកិច្ច

ការវិភាគសេដ្ឋកិច្ចក្នុងការត្រួតពិនិត្យជម្ងឺអុតក្តាមចំពោះក្រុមគ្រួសារ ២ប្រភេទ មានបង្ហាញជូនខាងក្រោម:

- ➢ គ្រួសារដែលមានគោប្រើជាកំលាំងអូសទាញចំនួន ២ក្បាល
- ➢ គ្រួសារដែលមានគោមេពូជចំនួន ១ក្បាល

ការវិភាគសេដ្ឋកិច្ចចំពោះគ្រួសារដែលមានគោប្រើជាកំលាំងអូសទាញចំនួន ២ក្បាល ក្នុងរយៈពេល ៣ខែ គឺនៅពេលចាប់ផ្តើមរដូវវស្សា បានបង្ហាញថា:

- ➢ ប្រសិនបើគោប្រើជាកំលាំងអូសទាញ២ក្បាល បានចាក់ថ្នាំបង្ការ២ដង គោទាំង២នោះគ្មានជម្ងឺកើតឡើងទេ
- ➢ ប្រសិនបើគោនោះមិនបានចាក់ថ្នាំបង្ការទេ ពួកវានឹងឈឺ ហើយជាលទ្ធផលកសិករត្រូវជួលសត្វគេមកដើម្បីភ្ជួររាស់ រៀបចំដី និងចំណាយលុយជាច្រើនលើការព្យាបាល(ជើងសត្វដើម្បីកុំឱ្យសត្វឈឺរយៈពេលយូរ) និងលើការទិញស្មៅពីព្រោះសត្វមិនអាចដើរស៊ីស្មៅដោយខ្លួនវាបាន ។ ជាលទ្ធផលការភ្ជួររាស់បានបញ្ចប់ទាន់ពេល ហើយគ្មានប៉ះពាល់ដល់ទិន្នផលស្រូវទេ ។ ជាការពិត ប្រសិនបើការផ្ទុះជម្ងឺមានទំហំធំធេង តម្លៃជួលកំលាំងភ្ជួររាស់ប្រហែលជាកើនឡើង បើយោងទៅលើកង្វះខាតកំលាំងសត្វសម្រាប់ភ្ជួររាស់។ លើសពីនេះទៅទៀតលក្ខខណ្ឌនៃរដូវ ប្រហែលជាអំណោយផលសម្រាប់ការផ្ទុះឡើង នៃជម្ងឺដែលធ្វើឱ្យមានការប៉ះពាល់ដល់ការរៀបចំដី ដូច្នេះទិន្នផលស្រូវអាចមានការប៉ះពាល់យ៉ាងខ្លាំង។ វាក៏បង្ហាញផងដែរថា នៅពេលដែលគោស្រកទម្ងន់ក្នុងកំឡុងពេលឈឺ។ នេះគឺការបង្កើតបញ្ហាដ៏ធំក្នុង កំឡុងពេលខែបន្តបន្ទាប់ ។

ការវិភាគនេះ បង្ហាញពីការបែរទៅរកការវិនិយោគលើការចាក់វ៉ាក់សាំងប្រកបដោយសក្តានុពលភាព។ គួរឱ្យកត់សំគាល់ផងដែរថា ឥទ្ធិពលនៃជម្ងឺអុតក្តាមនឹងប្រែប្រួលអាស្រ័យទៅលើពេលវេលានៃឆ្នាំ ។

**តារាងទី ៣ ការប្រៀបធៀបសេដ្ឋកិច្ចរវាងការអនុវត្តន៍ និងការមិនបានអនុវត្តការត្រួតពិនិត្យជម្ងឺអុតក្តាម ចំពោះគ្រួសារដែលមានគោកំលាំង២ក្បាលនៅដើមរដូវវស្សា**

| ការប្រៀបធៀបសេដ្ឋកិច្ចរវាងការអនុវត្តន៍ និងការមិនបានអនុវត្តការត្រួតពិនិត្យជម្ងឺអុតក្តាម ចំពោះគ្រួសារដែលមានគោកំលាំង២ក្បាលនៅដើមរដូវវស្សា | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **បរិយាយ** | **មិនមានការអនុវត្តន៍ការត្រួតពិនិត្យជម្ងឺអុតក្តាម** | | | | **អនុវត្តការត្រួតពិនិត្យជម្ងឺអុតក្តាម** | | | |
| | **ឯកតា** | **តម្លៃឯកតា** | **ចំនួនឯកតា** | **តម្លៃ(រៀល)** | **ឯកតា** | **តម្លៃឯកតា** | **ចំនួនឯកតា** | **តម្លៃ(រៀល)** |
| **តម្លៃប្រែប្រួល** | | | | | | | | |
| ការរៀបចំដី | ហិកតា | ៦០ ០០០ | ១,៥ | ៩០ ០០០ | ហិកតា | ៦០ ០០០ | ០ | ០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ការព្យាបាល | | ២០ ០០០ | ២ | ៤០ ០០០ | | ២០ ០០០ | ០ | ០ |
| វ៉ាក់សាំង | | ៦ ០០០ | ០ | ០ | | ៦ ០០០ | ៤ | ២៤ ០០០ |
| ចំណី | គ.ក្រ | ១០០ | ៩០ | ៩ ០០០ | គ.ក្រ | ១០០ | ០ | ០ |
| **តម្លៃសរុប** | | | | **១៣៩ ០០០** | | | | **២៤ ០០០** |

ការវិភាគសេដ្ឋកិច្ចចំពោះគ្រួសារ ដែលជាម្ចាស់មេគោ១ក្បាលឃើញថា មានប្រាក់ចំណេញយ៉ាងច្បាស់។ បើនិយាយឱ្យខ្លីគឺថា កូនគោនឹងងាប់ប្រសិនបើមេគោមិនបានចាក់វ៉ាក់សាំង។

**តារាងទី ៤ ការប្រៀបធៀបសេដ្ឋកិច្ចរវាងការអនុវត្ត និងការមិនបានអនុវត្តការត្រួតពិនិត្យជម្ងឺអុតក្ដាមចំពោះគ្រួសារដែលមានមេគោ១ក្បាល**

| ការប្រៀបធៀបសេដ្ឋកិច្ចរវាងការអនុវត្ត និងការមិនបានអនុវត្តការត្រួតពិនិត្យជម្ងឺអុតក្ដាម ចំពោះគ្រួសារដែលមានមេគោ១ក្បាល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **បរិយាយ** | **មិនមានអនុវត្តការត្រួតពិនិត្យជម្ងឺអុតក្ដាម** | | | | **អនុវត្តការត្រួតពិនិត្យជម្ងឺអុតក្ដាម** | | | |
| | **ឯកតា** | **តម្លៃឯកតា** | **ចំនួនឯកតា** | **តម្លៃ(រៀល)** | **ឯកតា** | **តម្លៃឯកតា** | **ចំនួនឯកតា** | **តម្លៃ(រៀល)** |
| **តម្លៃប្រែប្រួល** | | | | | | | | |
| កូនគោងាប់ | ក្បាល | ២០០ ០០០ | ១,០ | ២០០ ០០០ | ក្បាល | ២០០ ០០០ | ០ | ០ |
| ការព្យាបាល | | ២០ ០០០ | ១ | ២០ ០០០ | | ២០ ០០០ | ០ | ០ |
| វ៉ាក់សាំង | កំរិត | ៦ ០០០ | ០ | ០ | កំរិត | ៦ ០០០ | ២ | ១២ ០០០ |
| **តម្លៃសរុប** | | | | **២២០ ០០០** | | | | **១២ ០០០** |

ការវិភាគទាំងនេះ គួរតែទុកជាការណែនាំប៉ុណ្ណោះ។ នៅពេលគំនិតដែល (គ្មានការត្រួតពិនិត្យ) នឹងតែងតែបណ្ដាលឱ្យមានជម្ងឺកើតឡើង ហើយជម្ងឺមិនតែងតែបណ្ដាលឱ្យកូនគោងាប់ទេ ។




*គោដែលកើតជម្ងឺអុតក្ដាម ជាធម្មតាត្រូវទុកវានៅផ្ទះព្រោះវាឈឺចាប់នៅពេលដែលធ្វើចលនា*




*ជាទូទៅកសិករចំណាយពេលវេលាច្រើនក្នុងការប្រមូលចំណីឱ្យសត្វស៊ី នៅពេលដែលវាកើតជម្ងឺអុតក្ដាម*

## ៣. ការណែនាំលើការចុះផ្សព្វផ្សាយ

សេចក្ដីណែនាំក្នុងការផ្សព្វផ្សាយ រៀបរាប់អំពីកម្មវិធីផ្សព្វផ្សាយតាមឃុំ។ សេចក្ដីណែនាំទាំងនេះ អាចត្រូវបាន អនុម័តឱ្យធ្វើការផ្សព្វផ្សាយក្នុងតំបន់អនុវត្តន៍ធំៗ ដូចជា កំរិតស្រុក ខេត្ត ... ។

### *៣.១- ការរៀបចំស្ថាប័ន*

អ្នកដែលចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយគឺ៖

ក- មន្ត្រីនៃការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត-ក្រុង។ មន្ត្រីដែលជាសមាជិកនៅថ្នាក់នេះ ត្រូវទទួលខុសត្រូវចំពោះការសម្របសម្រួលនៃកម្មវិធីផ្សព្វផ្សាយ ។

ខ- មន្ត្រីបសុពេទ្យនៃការិយាល័យកសិកម្មស្រុក ក្រោមកិច្ចសន្យាដើម្បីរៀបចំសកម្មភាពការងារនៅក្នុងស្រុក។ ប្រធានការិយាល័យកសិកម្មស្រុកនឹងមានតួនាទីជាអ្នកគាំទ្រកម្មវិធីផងដែរ ។

គ- ចំពោះភ្នាក់ងារសុខភាពសត្វភូមិ ប្រសិនបើត្រូវបានបញ្ចូលទៅក្នុងសមាគមភ្នាក់ងារសុខភាពសត្វភូមិ នោះការរៀបចំផ្ទៃក្នុងរបស់សមាគមនេះ ត្រូវបានពិចារណា និងយកចិត្តទុកដាក់។ ឧទាហរណ៍ ប្រធាននៃសមាគម នេះមានតួនាទីសំខាន់ណាស់ក្នុងការដឹកនាំសមាគម ។

ឃ- អាជ្ញាធរភូមិ-ឃុំ ជាជំនួយក្នុងការអនុវត្តសកម្មភាពការងារនេះ ។

ង- អ្នកផ្គត់ផ្គង់វ៉ាក់សាំង។ ការផ្គត់ផ្គង់វ៉ាក់សាំងនេះ អាស្រ័យលើការបញ្ជាទិញ។

ច- កសិករចូលរួមផ្ដល់ព័ត៌មាន ចំណាយលើការទិញថ្នាំការពារ និងផ្ដល់ចំលើយតបស្ដីពីប្រសិទ្ធភាពនៃកម្មវិធីនេះ ។

### *៣.២- ផែនការសកម្មភាព*

ផែនការសកម្មភាពនេះមានរយៈពេលជាង៥ខែ រួមមាន ការបង្ហាញពីផែនការ ការអនុវត្តន៍ និងដំណាក់កាលពិនិត្យឡើងវិញ និងការវាយតម្លៃ។ នៅពេលអនុវត្តន៍កម្មវិធីត្រួតពិនិត្យដើម្បីទប់ទល់នឹងការផ្ទុះជម្ងឺអុតក្ដាម កម្មវិធីនេះ អាចត្រូវចាប់ផ្ដើមធ្វើនៅក្នុងពេលវេលាណាមួយនៃឆ្នាំ។ ការបង្ហាញជាឧទាហរណ៍ពីផែនការសកម្មភាព ដែលនឹងចាក់វ៉ាក់សាំងនៅខែឧសភាដូចខាងក្រោម៖

**ក្រាហ្វិកទី១ ផែនការសកម្មភាពសម្រាប់ការត្រួតពិនិត្យជម្ងឺអុតក្ដាម**

| ផែនការការងារសម្រាប់កម្មវិធីត្រួតពិនិត្យជម្ងឺអុតក្ដាម | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សកម្មភាពការងារ | ខែ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ការជ្រើសរើសទីកន្លែងអនុវត្តន៍ | | | | | | | | | | | | |
| ការប្រជុំនៅឃុំលើកទី១ ទី២ និងទី៣ | | | | | | | | | | | | |
| ការផ្សព្វផ្សាយដំណាក់កាល១ និង២ | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការចាក់វ៉ាក់សាំង | | | | | | | | | | | | |
| ការតាមដាន | | | | | | | | | | | | |
| ការប្រជុំយកចំឡើយតបពីកសិករ | | | | | | | | | | | | |
| ការត្រួតពិនិត្យអ្នកសំរបសំរួលថ្នាក់ស្រុក | | | | | | | | | | | | |
| ការត្រួតពិនិត្យថ្នាក់ខេត្ត | | | | | | | | | | | | |

**ការជ្រើសរើសទីកន្លែង**

គ្រប់ភូមិទាំងអស់នៅក្នុងឃុំ ត្រូវបានកំណត់ជាតំបន់គោលដៅ ចាប់តាំងពីជម្ងឺអុតក្តាមឆ្លងពីមួយភូមិទៅភូមិមួយមក ប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត-ក្រុង ត្រូវតែដឹងតំបន់សត្វស៊ីស្មៅ ដូចជាកន្លែងស៊ីស្មៅ និងទឹក និងរៀបចំកម្មវិធីត្រួតពិនិត្យជុំវិញតំបន់ទាំងនេះ ដែលមិនអាចជាន់គ្នាជាមួយព្រំដែនឃុំដទៃទៀត ។

**ការប្រជុំថ្នាក់ឃុំលើកទី១**

ការប្រជុំត្រូវរៀបចំដោយអ្នកគ្រប់គ្រងស្រុក និងចូលរួមដោយអាជ្ញាធរឃុំ និងភ្នាក់ងារសុខភាពសត្វភូមិ។ ការប្រជុំមានៈ

- ផ្នែកបច្ចេកទេសដែលចូលរួម ត្រូវលើកពីបញ្ហាបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់កម្មវិធីប្រយុទ្ធ ប្រឆាំងនឹងជម្ងឺអុតក្តាម និងស្ថានភាពជម្ងឺអុតក្តាមក្នុងខេត្ត-ក្រុង ស្រុក និងឃុំនាពេលបច្ចុប្បន្ន។ ចំពោះចំនួនគ្រួសារ និងចំនួនសត្វចិញ្ចឹមនៅក្នុងភូមិនីមួយៗនៃឃុំ គួរពិនិត្យឡើងវិញ។ ការបង្កើតឃុំគំរូដើម្បីធ្វើការចាក់ថ្នាំបង្ការជម្ងឺ រួចហើយធ្វើការប្រៀបធៀបជាមួយឃុំដទៃទៀត។ ភ្នាក់ងារសុខភាពសត្វភូមិ និងអ្នកបច្ចេកទេសត្រូវពិភាក្សាគ្នាដើម្បីចែករំលែកបទពិសោធន៍ក្នុងការចាក់ថ្នាំបង្ការ និងការព្យាបាលជម្ងឺអុតក្តាម។
- ការរំពឹងទុកថវិកាចំពោះកម្មវិធីចាក់ថ្នាំបង្ការជម្ងឺអុតក្តាម ។ ថវិកានេះរួមបញ្ចូលការប៉ាន់ប្រមាណនៃតម្រូវការចំនួនថ្នាំការពារ និងការចែកប្រាក់ចំណូល និងចំណេញរវាងភ្នាក់ងារសុខភាពសត្វភូមិ។ ប្រសិនបើប្រព័ន្ធនឹងត្រូវបានគេប្រើប្រព័ន្ធនេះ គួរត្រូវមានការពិភាក្សា និងឯកភាពដោយយោលទៅលើបរិមាណ និងប្រព័ន្ធចែកចាយ។
- ផ្នែករចនាសម្ព័ន្ធដែលរៀបរាប់អំពីផែនការសកម្មភាព រួមមាន ការផ្សព្វផ្សាយ ការចាក់វ៉ាក់សាំង ការតាមដាន និងវាយតម្លៃ។

**ការផ្សព្វផ្សាយលើកទី១**

ក្រុមភ្នាក់ងារសុខភាពសត្វភូមិ និងអាជ្ញាធរភូមិ ត្រូវសហការគ្នាដើម្បីផ្តល់ដំណឹងទៅកសិករតាមរយៈការពិភាក្សាក្រៅផ្លូវការមួយ ការជួបជុំជាក្រុម និងការចែកចាយចំណេះដឹងតាមរយៈខិត្តប័ណ្ណ និងផ្ទាំងរូបភាពបច្ចេកទេសពេលផ្ទុះជម្ងឺ ។

- ដំណឹងពីការផ្ទុះជម្ងឺអុតក្តាមនៅតំបន់ជិតខាង

- ពីការប្រើប្រាស់ និងតម្លៃវ៉ាក់សាំងជម្ងឺអុតក្តាម
- ប្រសិនបើត្រូវការចាក់វ៉ាក់សាំងជម្ងឺឱ្យសត្វរបស់គាត់ ពួកគាត់ត្រូវឱ្យថវិកាទៅភ្នាក់ងារសុខភាពសត្វភូមិដើម្បីទិញថ្នាំ និងបង់ថ្លៃបន្ថែមលើសេវា ។
- បញ្ជាក់ថាដើម្បីការពារសត្វគោ ក្របីរបស់គាត់ពីជម្ងឺអុតក្តាម ត្រូវយកគោ ក្របីរបស់គាតទៅចាក់ថ្នាំបង្ការឱ្យបាន២ដង។ ការចាក់ថ្នាំបង្ការលើកទី២ គឺចាក់នៅ១ខែក្រោយពីចាក់លើកទី១ ។
- បន្ថយឱ្យបានក្នុងកំរិតអប្បបរមា នូវចំនួនកសិករដែលត្រូវចំណាយលើថ្លៃថ្នាំបង្ការជាមុនសិន ដើម្បីឱ្យវាមានតម្លៃនៅពេលដែលភ្នាក់ងារសុខភាពសត្វភូមិផ្តល់សេវា ។

ភ្នាក់ងារសុខភាពសត្វភូមិត្រូវសហការជាមួយអាជ្ញាធរភូមិ ដើម្បីប្រមូលមូលនិធិពីកសិករដើម្បីទិញថ្នាំបង្ការ និងរក្សាទុកបង្កាន់ដៃដែលបានចំណាយ។

**ការប្រជុំថ្នាក់ឃុំលើកទី ២**

ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ ត្រូវជួបប្រជុំជាមួយអ្នកគ្រប់គ្រងស្រុកម្តងទៀតដើម្បីប៉ាន់ប្រមាណចំនួនថ្នាំបង្ការ តើត្រូវទិញបន្ថែមដើម្បីចែកចាយឬទេ? លើ៍សពីនេះ ភ្នាក់ងារសុខភាពសត្វភូមិគួរតែពិភាក្សាថា តើនឹងទិញវ៉ាក់សាំងបន្ថែមទៀតដែលលើសចំនួនថវិកាដែលមាននៅក្នុងមូលនិធិទេ? ក្នុងករណីកសិករផ្សេងទៀតត្រូវការវ៉ាក់សាំងបន្ថែម ពេលនោះភ្នាក់ងារសុខភាពសត្វភូមិគួរតែលើកគំរោង:

- បញ្ជាទិញ ប្រមូល និងចែកចាយវ៉ាក់សាំង
- រៀបចំសកម្មភាពផ្សព្វផ្សាយ
- រៀបចំកម្មវិធីចាក់ថ្នាំបង្ការ

## ការផ្សព្វផ្សាយលើកទី២

កំឡុងពេលនេះ ភ្នាក់ងារសុខភាពសត្វភូមិ និងអាជ្ញាធរដែនដីត្រូវសហការគ្នាជូនដំណឹងដល់កសិករ អំពីកាលបរិច្ឆេទនៃការចាក់ថ្នាំបង្ការតាមរយៈការពិភាក្សាក្រៅផ្លូវការ ការប្រកាសដោយប្រើមេក្រូបំពងសំលេង និងការចែកជូនផ្ទាំងរូបភាព ។

**ការចាក់វ៉ាក់សាំង**

ភ្នាក់ងារសុខភាពសត្វភូមិនៅជាក្រុម:

- ចែកចាយផ្ទាំងរូបភាព
- ដើរចាក់ថ្នាំបង្ការតាមផ្ទះ
- ប្រមូលសេវាថ្លៃចាក់ថ្នាំបង្ការ
- ចែកចាយខិត្តប័ណ្ណក្រោយពេលចាក់ថ្នាំបង្ការដល់កសិករដែលគាត់បានយកសត្វមកចាក់ថ្នាំបង្ការ
- កត់ត្រាការចាក់ថ្នាំបង្ការ

ការចាក់ថ្នាំបង្ការលើកទី២ ត្រូវធ្វើឡើងមួយខែក្រោយមក នៅពេលសត្វទាំងអស់ត្រូវការថ្នាំបង្ការលើកទី២។ ភ្នាក់ងារសុខភាពសត្វភូមិធ្វើការត្រួតពិនិត្យជាបន្ទាន់ឱ្យដឹងទាន់ពេលវេលាថាមានសត្វឈឺនៅក្នុងភូមិ ។

**ការតាមដាន**

ភ្នាក់ងារសុខភាពសត្វភូមិ បន្តការត្រួតពិនិត្យចំនួនសត្វដែលមាននៅក្នុងភូមិ ត្រួតពិនិត្យ និងព្យាបាលសត្វឈឺ និងកត់ត្រាករណីដែលសង្ស័យ ឬអះអាងថាជាករណីជម្ងឺអុតក្តាម ហើយធ្វើការទំនាក់ទំនងជាមួយអ្នកគ្រប់គ្រងស្រុក ប្រសិនបើមានករណីជម្ងឺផ្ទុះឡើង។ ការបន្តធ្វើបែបនេះរហូតដល់ពេលគេចាត់ទុកថាគ្រោះថ្នាក់នៃការផ្ទុះជម្ងឺនៅក្នុងតំបន់ជិតខាងបានស្ងប់ទៅវិញហើយ ដែលជាធម្មតាយ៉ាងហោចណាស់រយៈពេល៣ខែ ។

ភ្នាក់ងារសុខភាពសត្វភូមិគួរបន្តជួយជំរុញការចាក់ថ្នាំបង្ការ និងវិធានការការពារមួយចំនួនទៀត និងធ្វើការប្រមូលថវិកាដែលកសិករជំពាក់។ ភ្នាក់ងារសុខភាពសត្វភូមិគួរតែប្រាប់កសិករដោយប្រាកដនិយមថា គោ ក្របី ដែលមិនឈឺជម្ងឺអុតក្តាមនឹងត្រូវចាក់ថ្នាំបង្ការ ១ខែក្រោយបន្ទាប់ពីការចាក់ថ្នាំបង្ការលើកទី១ដើម្បីធានាថា សត្វមានប្រព័ន្ធការពារល្អ ។

**ការត្រួតពិនិត្យអ្នកសំរបសំរួលថ្នាក់ខេត្ត និងអ្នកគ្រប់គ្រងស្រុក**

អ្នកគ្រប់គ្រងស្រុក គួរតែចុះទៅត្រួតពិនិត្យឱ្យបានជាប្រចាំនៅកំឡុងពេលផ្សព្វផ្សាយ និងអនុវត្តការងារដើម្បីត្រួតពិនិត្យសកម្មភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិ និងពិភាក្សាបញ្ហាផ្សេងៗជាមួយកសិករ។ អ្នកសំរបសំរួលថ្នាក់ខេត្តគួរចុះទៅមើលក្នុងឃុំ យ៉ាងហោចណាស់មួយដងក្នុងដំណាក់កាលនីមួយៗនៃកម្មវិធី ហើយចូលរួមប្រជុំចុងក្រោយនៅក្នុងឃុំ ។

**ការប្រជុំយកចំលើយតបពីកសិករ**

ការប្រជុំជាសាធារណៈដើម្បីឆ្លើយតបទៅកសិករ ត្រូវរៀបឡើងនៅក្នុងឃុំដើម្បីធ្វើការពិភាក្សា និងចែករំលែកបទពិសោធន៍ផ្សេងៗនៃកម្មវិធីធ្វើយុទ្ធនាការចាក់ថ្នាំបង្ការ។ ការប្រជុំនេះត្រូវរៀបចំឡើងដោយអ្នកគ្រប់គ្រងស្រុក និងអាជ្ញាធរដែនដី និងមានការចូលរួមពីកសិករ និងភ្នាក់ងារសុខភាពសត្វភូមិ ។

**ការប្រជុំថ្នាក់ឃុំលើកទី៣**

ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ ត្រូវមកជួបប្រជុំជាមួយអ្នកគ្រប់គ្រងស្រុកម្តងទៀត ដើម្បីវាយតម្លៃលទ្ធផលកម្មវិធីត្រួតពិនិត្យ ដោយផ្អែកទៅលើចំណេះដឹង និងការចូលរួមរបស់កសិករ ហើយនិងការត្រួតពិនិត្យជម្ងឺ និងប្រាក់ចំណូលរបស់ភ្នាក់ងារសុខភាពសត្វភូមិ។ អ្នកដែលពាក់ព័ន្ធទាំងអស់គួរតែពិភាក្សាពីភាពខ្លាំង ភាពខ្សោយ និងអនុសាសន៍សម្រាប់ពេលអនាគត ។ **៣.៣- ឧបករណ៍, សម្ភារៈ**

សម្ភារៈ និងឧបករណ៍ដូចខាងក្រោមនេះ គឺត្រូវការជាចាំបាច់ក្នុងពេលអនុវត្តន៍ (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)

**តារាងទី៥ បញ្ជីឧបករណ៍ និងសម្ភារៈ**

| |
|---|
| សៀវភៅសម្រាប់កត់ត្រាអ្នកគ្រប់គ្រងក្នុងភូមិ |
| សៀវភៅកត់ត្រាសម្រាប់អ្នកគ្រប់គ្រងក្នុងភូមិ |
| ក្តារខៀនផ្សព្វផ្សាយពីជម្ងឺអុតក្តាម |
| ខិត្តប័ណ្ណព័ត៌មានជម្ងឺអុតក្តាម |
| ផ្ទាំងរូបភាពថ្ងៃចាក់ថ្នាំការពារជម្ងឺអុតក្តាម |
| ខិត្តប័ណ្ណក្រោយពេលចាក់ថ្នាំការពារជម្ងឺអុតក្តាម |
| ប័ណ្ណតំណាងសាច់ប្រាក់ |
| ឯកសារបច្ចេកទេសជម្ងឺអុតក្តាមសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ |

សៀវភៅបណ្ដុះបណ្ដាលភ្នាក់ងារសុខភាពសត្វភូមិ អាចរកបាននៅការិយាល័យផលិតកម្ម និងបសុព្យាបាល ខេត្ត ដែលជាប្រភពព័ត៌មានស្ដីពីបញ្ហាសុខភាព និងការគ្រប់គ្រងសត្វ ដូចជា ខិត្តប័ណ្ណ ផ្ទាំងរូបភាព ក្ដារខៀនរូបភាព និង សៀវភៅកត់ត្រាដែលមាននៅក្នុងឧបសម្ព័ន្ធ។

ប្រព័ន្ធប័ណ្ណតំណាងសាច់ប្រាក់ គឺជាសកម្មភាពជម្រើសដ៏ល្អ ហើយប្រព័ន្ធប័ណ្ណតំណាងសាច់ប្រាក់ គឺធ្វើការងារ ដូចខាងក្រោម:

- ប័ណ្ណតំណាងសាច់ប្រាក់នៃចំនួនដែលបានកំណត់ក្នុងមួយភូមិ ត្រូវបានចែកជូនកសិករដែលសមស្រប តាមលក្ខខណ្ឌជ្រើសរើស (តួយ៉ាងដូចជា កសិករដែលក្រីក្រមានគោតែមួយ) ដោយប្រធានភូមិក្នុង កំឡុងពេលផ្សព្វផ្សាយ។ ប័ណ្ណតំណាងសាច់ប្រាក់ទាំងនេះមានតម្លៃ ៦០០០រៀល (តម្លៃថ្នាំការពារ មួយដូស) ហើយតម្លៃ និងគោលបំណងនៃប័ណ្ណតំណាងសាច់ប្រាក់នេះ មានបង្ហាញជូននៅលើប័ណ្ណ តំណាងនេះតែម្ដង។ មេភូមិធ្វើការកត់ត្រាចំនួនប័ណ្ណតំណាងសាច់ប្រាក់ដែលបានចែកចាយ និងការ ផ្ដល់ដល់ ភ្នាក់ងារសុខភាពសត្វភូមិ ។
- កសិករ ត្រូវរក្សាទុកប័ណ្ណតំណាងសាច់ប្រាក់នេះរហូតដល់ថ្ងៃចាក់ថ្នាំការពារមកដល់
- កសិករ ត្រូវអោយប័ណ្ណតំណាងសាច់ប្រាក់នេះដល់ភ្នាក់ងារសុខភាពសត្វភូមិ ជំនួសថវិកាចំណាយលើ ការចាក់ថ្នាំការពារ។
- ភ្នាក់ងារសុខភាពសត្វភូមិ បង្ហាញប័ណ្ណតំណាងសាច់ប្រាក់នេះនៅពេលប្រជុំថ្នាក់ឃុំបញ្ចប់ និងទូទាត់ យោលទៅលើចំនួននៃប័ណ្ណតំណាងសាច់ប្រាក់ ។

គោលបំណងនៃការរៀបចំប្រព័ន្ធប័ណ្ណតំណាងសាច់ប្រាក់នេះ គឺដើម្បីពង្រីកទស្សនៈនៃកម្មវិធីផ្សព្វផ្សាយនិងទុក សម្រាប់ការប្រើប្រាស់មូលនិធិឱ្យចំក្រុមគោលដៅនៅក្នុងភូមិ។ វាតម្រូវឱ្យមានបែបបទរដ្ឋបាលខ្លះ និងមានហានិភ័យ សេដ្ឋកិច្ច ពីសំណាក់ភ្នាក់ងារសុខភាពភូមិដែលបានទិញវ៉ាក់សាំងដោយប្រាក់ផ្ទាល់ខ្លួន ហើយសង្ឃឹមថាអាចបានប្រាក់នោះ មកវិញ។ ទាំងនេះប្រហែលជាសមស្របទៅនឹងស្ថានភាពខ្លះ និងមិនសមស្របខ្លះ ដូច្នេះវាជាសកម្មភាពមួយដែលមាន ប្រយោជន៍។

## ៣.៤- ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្តែងនៃសាម៉ីអង្គភាព។ តារាងថវិកាខាងក្រោមបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដោយយោងទៅលើការប៉ាន់ស្មាន លើបទដ្ឋានអនុវត្តបច្ចេកវិទ្យារបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

**តារាងទី៦ ៖ថវិកាសម្រាប់អនុវត្តន៍គំរោង**

| **ថវិកា និង ការសន្មត់** | ចំនួន / តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ១០០០គោ/ក្របី/ ឃុំ |
| ទុនសម្រាប់វ៉ាក់សាំងអុតក្តាម (ខ) | $១០០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (គ)<br>- ឯកសារ / ការណែនាំពីបច្ចេកវិទ្យា TIP | $២០០ |
| ទិវាស្រែ - សំភារៈ (ឃ) | $២៤០០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ង)<br>- ការបណ្តុះបណ្តាល,ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $១៧៥ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ច) | $១០០ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេស (ឆ) | $៤០ |
| សរុប | **$៣០១៥** |

**ការសន្មត់ប្រើប្រាស់មាន**

ក. ក្នុង TIP មួយ មានជ្រូកកសិករចំនួន ១០០០ជ្រូក ក្នុងមួយឃុំ

ខ. កម្មវិធីចាក់វ៉ាក់សាំងសត្វពាហនៈ (អុតក្តាម-ថ្នាក់ឃុំ)ដោយពឹងផ្អែកលើប្រព័ន្ធ (ខ័ណ្ឌប័ណ្ណ) ហើយសំភារៈទាំងអស់ត្រូវបានឧបត្ថម្ភ/ផ្គត់ផ្គង់។ ទុនសម្រាប់វ៉ាក់សាំងការពារនេះ មានរួមបញ្ចូលទាំង ការធ្វើផែនការ ២ ដំណាក់ និង ការប្រជុំដើម្បីត្រួតពិនិត្យតាមដាន ២ ដំណាក់កាល ។

គ. សំភារៈសម្រាប់បណ្តុះបណ្តាលបច្ចេកវិទ្យាដល់កសិកររួមមាន ធុងទឹកកក តម្លៃ ៥០ដុល្លា ខិត្តប័ណ្ណ៥០ដុល្លា ផ្ទាំងរូបភាពធំ៧ ៥០ដុល្លារ និងព័ត៌មានកម្មវិធី ៥០ដុល្លា សរុបទាំងអស់ = ២០០ ដុល្លារ។ មន្ត្រីផលិតកម្មនិងបសុព្យាបាលនៃ ការិយាល័យ កសិកម្មស្រុក ចូលរួមប្រជុំ ៤ ដង រួមទាំងការចុះវាល។

ឃ. ការចាក់វ៉ាក់សាំងការពារជម្ងឺអុតក្តាម=4២៤០០ (៤៨០០រៀលក្នុង ១ dose x២dose x១០០០ក្បាល) កម្មវិធីនេះ នឹងអនុវត្តអោយចប់ក្នុងរយៈពេល៥ថ្ងៃប៉ុណ្ណោះ ដោយត្រូវប្រើកំលាំងភ្នាក់ងារពេទ្យសត្វភូមិ ចំនួន ១០នាក់

ង. សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភប្រចាំថ្ងៃ សរុបទាំងអស់ ៥០ថ្ងៃ ដោយមានភ្នាក់ងារពេទ្យ សត្វភូមិចំនួន១០នាក់

ច. ប្រាក់ឧបត្ថម្ភសម្រាប់ធ្វើដំណើរ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ៥០ថ្ងៃ

ឆ. មន្ត្រីឯកទេសជំនាញការិយាល័យកសិកម្មស្រុក- អ្នកផ្តល់ជំនួយបច្ចេកទេសនិងត្រួតពិនិត្យតាមដានការបណ្តុះបណ្តាល បអប

### ៣.៥- ទីកន្លែងអនុវត្តន៍គំរោង

សកម្មភាពទាំងអស់នេះ ត្រូវបានអនុវត្តលើមូលដ្ឋានមិនផ្លូវការមួយក្នុងខេត្តជាច្រើនដូចជា ខេត្តកំពង់ធំ ប៉ុន្តែមិនមានការឧបត្ថម្ភជាផ្លូវការទេ។ ការអន្តរាគមន៍របស់រដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជម្ងឺអុតក្តាមនៅក្នុងភូមិ ជាធម្មតាបានអនុវត្តន៍ក្នុងទម្រង់ទិញ និងចែកចាយថ្នាំបង្ការក្នុងលក្ខណៈសង្គ្រោះបន្ទាន់។

# ៤. ឧបសម្ព័ន្ធ

## *៤.១ ឧបសម្ព័ន្ធទី ១  សៀវភៅកត់ត្រាសម្រាប់អ្នកគ្រប់គ្រងស្រុក*

| កម្មវិធីប្រយុទ្ធនឹងជម្ងឺអុតក្តាម | | |
|---|---|---|
| សៀវភៅកត់ត្រារបស់អ្នកគ្រប់គ្រងស្រុក | | |
| កំណត់ត្រាកិច្ចប្រជុំថ្នាក់ឃុំលើកទី ២ | | |
| ឈ្មោះ និងតួនាទីរបស់អ្នកគ្រប់គ្រងស្រុក<br>កាលបរិច្ឆេទថ្ងៃប្រជុំ<br>ខេត្ត<br>ស្រុក<br>ឃុំ | | |
| បញ្ជីឈ្មោះអ្នកចូលរួម | | |
| ល | ឈ្មោះ | តួនាទី |
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ៥ | | |
| ៦ | | |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |

| ក្រុមចាក់វ៉ាក់សាំង និង គំរោងទិញវ៉ាក់សាំង | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ភូមិ | ឈ្មោះ ក្រុម ភ្នាក់ងារ ស ស ភ | ចំនួនគ្រួសារ ដែលបានបង់ប្រាក់ | ចំនួនគោ ក្របី ដែលបានវ៉ាក់សាំង | ចំនួនជ្រូកដែល បានចាក់វ៉ាក់សាំង | ថវិកាដែល បានប្រមូល (រៀល) | ចំនួនវ៉ាក់សាំង ដែលបានចាក់ | ចំនួនវ៉ាក់សាំង ដែលទិញបន្ថែម |
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| ៥ | | | | | | | | |
| ៦ | | | | | | | | |
| ៧ | | | | | | | | |
| ៨ | | | | | | | | |
| ៩ | | | | | | | | |
| ១០ | | | | | | | | |

# កម្មវិធីប្រយុទ្ធនឹងជម្ងឺអុតក្តាម

សៀវភៅកត់ត្រារបស់អ្នកគ្រប់គ្រងស្រុក

កំណត់ត្រាកិច្ចប្រជុំថ្នាក់ឃុំលើកទី ៣

ឈ្មោះ និងតួនាទីរបស់អ្នកគ្រប់គ្រងស្រុក

កាលបរិច្ឆេទថ្ងៃប្រជុំ

ខេត្ត

ស្រុក

ឃុំ

បញ្ជីឈ្មោះអ្នកចូលរួម

| ល | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ៥ | | |
| ៦ | | |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |

ក្រុមចាក់វ៉ាក់សាំង និង តំរោងទិញវ៉ាក់សាំង

| | ភូមិ | កាលបរិច្ឆេទថ្ងៃ ចាក់វ៉ាក់សាំង | ចំនួនគោ ក្របី ដែលបានចាក់វ៉ាក់សាំង | ចំនួនជ្រូកដែល បានចាក់វ៉ាក់សាំង | សរុបប្រាក់ ចំណូល(រៀល) | សរុបប្រាក់ជពាក់ (រៀល) | សរុបតម្លៃ វ៉ាក់សាំង(រៀល | សរុបប្រាក់ ចំណេញ(រៀល) |
|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| ៥ | | | | | | | | |
| ៦ | | | | | | | | |
| ៧ | | | | | | | | |
| ៨ | | | | | | | | |
| ៩ | | | | | | | | |
| ១០ | | | | | | | | |

ការបែងចែកសម្ភារៈផ្សព្វផ្សាយ

| | | | | | | |
|---|---|---|---|---|---|---|
| ១ | ខិត្តប័ណ្ណព័ត៌មានស្តីពីជម្ងឺអុតក្តាម | | | | | |
| ២ | ផ្ទាំងរូបភាពថ្ងៃចាក់វ៉ាក់សាំង | | | | | |
| ៣ | ខិត្តប័ណ្ណក្រោយពេលចាក់វ៉ាក់សាំង | | | | | |
| ៤ | ប័ណ្ណតំណាងសាច់ប្រាក់ | | | | | |
| ៥ | ប័ណ្ណព័ត៌មានខ្លីៗ | | | | | |

១. តើកសិករបានយល់ដឹងពីជម្ងឺអុតក្តាម មានចំនួនប៉ុន្មានភាគរយ? មុនពេលផ្សព្វផ្សាយ និងក្រោយពេលផ្សព្វផ្សាយ

| | |
|---|---|
| ២. | តើកសិករកសិករប៉ុន្មានភាគរយមានឆន្ទៈចំណាយថវិកាលើការចាក់ថ្នាំបង្ការជម្ងឺអុតក្តាម ? មុនពេលផ្សព្វផ្សាយ និងក្រោយពេលផ្សព្វផ្សាយ |
| ៣. | តើមានជម្ងឺអ្វីផ្ទុះឡើងលើសត្វគោ ក្របីក្រោយពេលចាក់វ៉ាក់សាំង? មុនពេលផ្សព្វផ្សាយ និងក្រោយពេលផ្សព្វផ្សាយ<br>ផ្តល់សេចក្តីពិស្តារ |
| ៤. | តើអ្វីជាភាពខ្សោយក្នុងពេលចុះធ្វើការផ្សព្វផ្សាយ ? |
| ៥. | តើអ្វីជាភាពខ្លាំងក្នុងពេលចុះធ្វើការផ្សព្វផ្សាយ ? |
| ៦. | តើអាចមានវិធីណាដើម្បីធ្វើឱ្យការផ្សព្វផ្សាយមានភាពប្រសើរឡើង? |

## ៤.២ ឧបសម្ព័ន្ធទី ២  សៀវភៅកត់ត្រាសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ

កម្មវិធីប្រយុទ្ធនឹងជម្ងឺអុតក្តាម

កំណត់ត្រារបស់ភ្នាក់ងារសុខភាពសត្វភូមិ

ការផ្សព្វផ្សាយលើកទី ១

ខេត្ត

ស្រុក

ឃុំ

ភូមិ

សមាជិកក្រុមពេទ្យសត្វភូមិ

កាលបរិច្ឆេទ

| ល | ឈ្មោះគ្រួសារ | សរុបប្រាក់ចំណាយ (រៀល) | ចំនួនគោ ក្របី ដែលបានចំណាយលើការចាក់វ៉ាក់សាំង(ក្បាល) | ចំនួនជ្រូក ដែលបានចំណាយលើការចាក់វ៉ាក់សាំង(ក្បាល) | សរុបចំនួនវ៉ាក់សាំង(ដូស) | សរុបចំនួនវ៉ាក់សាំង(ដប) |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |
| សរុប | | | | | | |

# កម្មវិធីប្រយុទ្ធនឹងជម្ងឺអុតក្តាម

កំណត់ត្រារបស់ភ្នាក់ងារសុខភាពសត្វភូមិ

ការវ៉ាក់សាំង និង ការតាមដាន

ខេត្ត

ស្រុក

ឃុំ

ភូមិ

សមាជិកក្រុមពេទ្យសត្វភូមិ

កាលបរិច្ឆេទការចាក់ថ្នាំបង្ការ

| ល | ឈ្មោះគ្រួសារ | ចំនួនគោ ក្របី ដែល បានចាក់វ៉ាក់សាំង | ចំនួនជ្រូក ដែល បានចាក់វ៉ាក់សាំង | សរុបការ ចំណាយមុន | សរុបថវិកាចំណាយ លើវ៉ាក់សាំង (រៀល) | សរុបថវិកាជំពាក់ (រៀល) |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |
| សរុប | | | | | | |

## ៤.៣ ឧបសម្ព័ន្ធទី ៣  ខិត្តប័ណ្ណព័ត៌មានអំពីជម្ងឺអុតក្តាម

ជម្ងឺអុតក្តាមអាចធ្វើ ឱ្យគោរបស់អ្នកឈឺរយៈពេល ២-៣សប្តាហ៍
គោឈឺមាត់ កំលាំងខ្សោយ ដើរពុំរួចរយៈពេល ២-៣ សប្តាហ៍



កូនគោមិនអាចបៅដោះមេបានងាយស្រួលឡើយ ហើយខ្លះ
អាចងាប់ ប្រសិនបើជម្ងឺវាយប្រហារនៅលើបេះដូង



កូនជ្រូកអាចងាប់ ឬ លូតលាស់យឺត



ការចាក់ថ្នាំបង្ការអាចការពារគោ ក្របី ជ្រូករបស់អ្នកពីជម្ងឺអុតក្តាម



វ៉ាក់សាំងជម្ងឺអុតក្តាម
តម្លៃ ............... រៀល ក្នុង ១ក្បាល

វ៉ាក់សាំងជម្ងឺអុតក្តាមមិនអាចការពារជម្ងឺគោ
ក្របី ជ្រូក ពីជម្ងឺផ្សេងទៀតបានទេ



**ចំពោះព័ត៌មានបន្ថែម សូមទាក់ទងភ្នាក់ងារសុខភាពសត្វភូមិ**

## ៤.៤ ឧបសម្ព័ន្ធទី ៤ ផ្ទាំងរូបភាព និងខិត្តប័ណ្ណផ្សព្វផ្សាយពីការផ្ទុះជម្ងឺអុតក្តាម

**ការផ្ទុះជម្ងឺអុតក្តាម**



មានជម្ងឺអុតក្តាមផ្ទុះឡើងនៅក្នុង .................................

ជម្ងឺអុតក្តាមប្រហែលជាអាចកើតមាននៅក្នុងភូមិនេះក្នុងពេលឆាប់នេះ ហើយនឹងអាចឆ្លងដល់គោ ក្របី និងជ្រូករបស់លោកអ្នក

ភ្នាក់ងារសុខភាពសត្វភូមិកំពុងរៀបចំចាក់វ៉ាក់សាំងសត្វនៅក្នុងភូមិនេះដើម្បីការពារសត្វគោ ក្របី និងជ្រូករបស់អ្នក

វ៉ាក់សាំងតម្លៃ ................................ រៀលក្នុង ១ក្បាល

**ចំណាយថវិកាទៅឱ្យភ្នាក់ងារសុខភាពសត្វភូមិ**
**ទើបពួកគាត់មានថវិកាសម្រាប់ទិញវ៉ាក់សាំង**

## ៤.៥ ឧបសម្ព័ន្ធទី ៥  ផ្ទាំងរូបភាព ផ្សព្វផ្សាយពីថ្ងៃចាក់វ៉ាក់សាំងជម្ងឺអុតក្តាម

### ទិវាចាក់ថ្នាំបង្ការដើម្បីការពារជម្ងឺអុតក្តាម



ថ្ងៃ ខែ ឆ្នាំ  :

ទីកន្លែង  :

ម៉ោង  :

តម្លៃ  :

**សូមរង់ចាំនៅផ្ទះរបស់លោកអ្នក**

**អ្នកចាក់វ៉ាក់សាំងនឹងទៅដល់ផ្ទះរបស់លោកអ្នក**

**ដើម្បីចាក់វ៉ាក់សាំងដល់សត្វរបស់លោកអ្នក**

## *៤.៦ ឧបសម្ព័ន្ធទី ៦  ខិត្តប័ណ្ណក្រោយពេលចាក់វ៉ាក់សាំងជម្ងឺអុតក្តាម*

គោ ក្របី និងជ្រូករបស់អ្នកបានចាក់វ៉ាក់សាំង

ដើម្បីការពារជម្ងឺអុតក្តាម



ការចាក់វ៉ាក់សាំងនេះ នឹងជួយការពារសត្វរបស់អ្នកពីជម្ងឺ

អុតក្តាម រយៈពេល៦-៩ខែ



ការចាក់វ៉ាក់សាំងជម្ងឺអុតក្តាម មិនអាចការពារគោ ក្របី

របស់អ្នកពីជម្ងឺដទៃទៀតឡើយ ដូចជាជម្ងឺសាទឹក ជាដើម



ការចាក់វ៉ាក់សាំងជម្ងឺអុតក្តាម មិនអាចការពារជ្រូក

របស់អ្នកពីជម្ងឺដទៃទៀតឡើយ ដូចជាជម្ងឺប៉េស្តជ្រូក



**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង**

**ភ្នាក់ងារសុខភាពសត្វភូមិ**

## ៤.៧ ឧបសម្ព័ន្ធទី ៧   ព័ត៌មានខ្លីៗសម្រាប់ផ្សព្វផ្សាយជម្ងឺអុតក្តាម

